## ជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

### អបអរសាទរ ទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣


**យុវតី យឹម សុនីតា**

*ជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យសម្តេចតេជោហ៊ុនសែន រលាំងឈូក ខេត្តកំពង់ស្ពឺ*


### ចំណងជើងកំណាព្យ៖ «អំណានជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត»

(កំណាព្យបទ ពាក្យប្រាំពីរ)

១- កវីនិពន្ធជូនតាខ្មែរ    លោករក្សាថែវប្បធម៌ជាតិ
ច្បាប់ក្បួនទំនៀមមិនរវាត    កូនចៅឯទៀតបានយល់ដឹង។

២- អំណានជាថ្នាលបានជួយផ្តល់    ចំណេះតម្កល់ផលប្រែងប្រឹង
ចេះគិតត្រិះរិះគ្រប់ដំណឹង    ចេះថ្លែងចេះថ្លឹងគ្រប់ប្រាជ្ញា។

៣- អំណានបណ្តុះការសិក្សា    ពលរដ្ឋខេមរាគ្រប់ជន្មា
រៀនសូត្រនៅគ្រប់ពេលវេលា    ចំណេះវិជ្ជាបានថ្កើងថ្កាន។

៤- អំណានអានច្រើនកើនប្រាជ្ញា    ស្មារតីភ្លឺថ្លាដ៏ចំណាន
សិក្សាស្រាវជ្រាវតាមលំអាន    សុខកាយស្រួលប្រាណបានជោគជ័យ។

៥- អំណានអភិវឌ្ឍយ៉ាងថ្លាថ្លៃ    ផ្តល់គុណតម្លៃដ៏ប្រពៃ
អានកើននូវបញ្ញាវាងវៃ    យុវជនលកលៃតាមគ្រឹះស្ថាន។

៦- អំណានអំណាចផ្ទុះគំនិត    ជ្រោមជ្រែងការគិតដោយក្សេមក្សាន្ត
មនុស្សគ្រប់រូបរស់នៅបាន    វិជ្ជាចំណានប្រាណជុំជិត។

៧- អំណានតាមបែបវិទ្យាសាស្ត្រ    សិក្សាយ៉ាងច្បាស់យល់គំនិត
ផ្តល់នូវការច្នៃដល់ជីវិត    ជុំរុញការគិតមិត្តគ្នីគ្នា។

៨- អំណានកើតមានសន្តិភាព    បណ្តុះជ្រួតជ្រាបដល់ជនា
រៀនអានគ្រប់វ័យដល់ជរា    ទោះពេលនិទ្រាអានជានិច្ច។

៩- អំណានគន្លឹះការអប់រំ    រៀនសូត្រខិតខំផលរំលេច
ស្វះស្វែងប្រឹងប្រែងស្តារសេដ្ឋកិច្ច    មិនត្រូវកែគេចខ្ជិលនោះឡើយ។

១០- អរគុណសន្តិភាពជួយផ្តល់    ចំណេះតម្កល់ផលដល់ត្រើយ
ត្រួសត្រាយគោលដៅបានធូរស្បើយ    កាយបានរហើយតកូនចៅ។

## ជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ
## «ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន»
## អបអរសាទរ ទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣

**យុវតី អ៊ឹម អែម**

*ជាសិស្សថ្នាក់ទី១១ នៃវិទ្យាល័យកំពង់ធំ ខេត្តកំពង់ធំ*

**ចំណងជើងកំណាព្យ៖ «អំណានជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- យុវជនយើងចូរចងចាំ គ្រូបាបានផ្ដាំដូច្នេះថា
ដើម្បីធ្វើឱ្យការសិក្សា បានជោគជ័យថ្លាគ្រប់ៗប្រាណ។
២- គ្មានជនណាកើតមកចេះស្រាប់ ត្រូវរៀនប្រឹងស្ដាប់និងតាមដាន
ខំមើលបន្ថែមកុំបីខាន ព្រមទាំងរៀនអានឱ្យរត់មាត់។
៣- អានច្រើនគិតច្រើនកើនចំណេះ ប្រឹងរៀនឱ្យចេះកុំឱ្យភ្លាត់
ហាត់អានអំណានឱ្យចេះស្ទាត់ និងអនុវត្តដោយជាក់ស្ដែង។
៤- អានច្រើនចេះច្រើនកើនប្រាជ្ញា ស្មារតីភ្លឺថ្លាគេកោតក្រែង
ទទួលជោគជ័យបានតំណែង សិស្សពូកែតែងមកពីអាន។
៥- អំណានគឺជាមូលដ្ឋានគ្រឹះ ជួយស្រាយគន្លឹះជនគ្រប់ប្រាណ
ផ្សព្វផ្សាយវិជ្ជាគ្រប់មូលដ្ឋាន គំនិតថ្កើងថ្កានរីកដុះដាល។
៦- អានច្រើនមើលច្រើនកើនការគិត បណ្ដុះគំនិតពាសពេញថ្ពាល
វិជ្ជាថ្មីចាស់ផុសចេញព្រោល វិសេសវិសាលសមុដ្ឋាន។
៧- អំណានជួយបានដល់សង្គម វិស័យអប់រំគ្រប់មជ្ឈដ្ឋាន
ជួយអភិវឌ្ឍនៃគ្រឹះស្ថាន សេដ្ឋកិច្ចរីកបានដូចបំណង។
៨- ដើម្បីលើកស្ទួយប្រទេសជាតិ កុលបុត្រខ្មីឃ្មាតត្រូវតបស្នង
ដោយយកអំណានជាស្ពានឆ្លង សម្រាប់ចម្លងឱ្យជាក់ច្បាស់។
៩- មានវិជ្ជាហើយកុំភ្លេចណា ត្រូវយកបញ្ញាមកប្រើប្រាស់
ជួយស្ដារប្រទេសឱ្យប្ដូរផ្លាស់ ពីភាពចំណាស់ទៅជាថ្មី។
១០- ដើម្បីឱ្យជាតិចម្រើនឡើង ត្រូវលើកតម្កើងសព្វអ្វីៗ
អក្សរសាស្ត្រខ្មែរអំណានក្ដី កូនខ្មែរប្រុសស្រីត្រូវរក្សា៕

# ជ័យលាភីលេខ៣ ផ្នែកតែងនិពន្ធ

## «ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន»

## អបអរសាទរ ទិវាជាតិអំណានលើកទី៨ ១១ មីនា ២០២៣

**យុវជន សុភាជ វិសិដ្ឋ**

*សិស្សថ្នាក់ទី១១ នៃវិទ្យាល័យមេសាង ខេត្តព្រៃវែង*

**ចំណងជើងកំណាព្យ៖ «អំណានជាមូលដ្ឋានគ្រឹះនៃការសិក្សាពេញមួយជីវិត»**

(កំណាព្យបទ ពាក្យប្រាំពីរ)

១- ជីវិតថ្លាថ្លៃក្រៃឧត្តម
សុសសាយសក្តិសមសព្វទិសា
ល្បីល្បាញរន្ទឺលើលោកា
ថ្កុំថ្កើងដោយសារការអប់រំ។

២- បំប៉ននូវគុណសម្បទា
សិក្សាគ្រប់គ្នាក្នុងសង្គម
ច្បងច្បាស់ជំនាញកិច្ចការធំ
បេះដាក់គ្រប់មុំមិនធ្វេសទេ្វ។

៣- បណ្តុះបំណិនធ្និនវិជ្ជា
ផ្ទៅសព្វមាគ៌ាឥតងាករេ
កើតកើនពុទ្ធិពុំទន់ទេរ
ទទួលទុនផ្ទេរពីដូនតា។

៤- កសាងវិធីសាស្រ្តបង្រៀន
សព្វសិល្ប៍រៀនមានតម្រា
បង្កើតកម្មវិធីសិក្សា
តបតាមផែនការយុទ្ធសាស្រ្ត។

៥- រីការខិតខំស្វះស្វែងរៀន
តម្រូវឱ្យមានភាពច្បងច្បាស់
ជំនាញទន់រឹងខ្លាំងក្រៃក្រាស់
រុងរឿងរហ័សរីកស្គុសស្គាយ។

៦- មូលដ្ឋានជីវិតមាំមួនធន់
ដោយការគិតគន់មិនទន់ជ្រាយ
លើកកម្ពស់អានឱ្យទូលាយ
អានដោយសម្វាយគ្រប់វេលា។

៧- អានឥតកន្ដើយដោយគម្លាន
បំប៉នរបៀនសម្បទា
បណ្តុះធនធានមានវិជ្ជា
ស្របនឹងនវានុវត្តន៍ស្តែង។

៨- អានជាឫសក្លាយប្រាជ្ញប្រាយគ្រូ
កើតកើនវិញ្ញូរះចិញ្ចែង
ចិញ្ចាចមោះមុតគ្រប់កន្លែង
ជាជនតាក់តែងព្រលឹងញាណ។

៩- យុគឌីជីថលដើរដល់ស្រាប់
តាមទូរស័ព្ទចាប់ជាយាន
កុំព្យូទ័រទៀតញាតិព្រៀងលាន
ខិតខំឈោងឈានរៀនប្រើប្រាស់។

១០- អានឱ្យយល់ដឹងរូបមន្ត
គណិតនព្វន្តវិទ្យាសាស្រ្ត
បច្ចេកវិទ្យាចងជាក់ច្បាស់
ដុះដាលដេរដាសក្រាស់ហូរហៀរ។

១១- សតវត្សថ្មីទីម្ភៃមួយ
លើលោកលើកស្ទួយឱ្យស្ទុះស្ទា
ដោយយុវជនគ្រប់អង្គា
បន្តវេនគ្នាជាទីពឹង។

១២- ល្ពឹកសិស្សនិស្សិត សព្វប្រជា
អានដោយម្ចីម្នានិត្យជញ្ជឹង
ជញ្ជក់ជំនាញទាំងទន់រឹង
សង្គមជាតិនឹងអភិវឌ្ឍ។

១៣- ចក្ខុវិស័យការអប់រំ
កសាងសង្គមឱ្យធំជាត់
ធូរធារថ្កើងថ្កានបានពលរដ្ឋ
រុងរឿងមុខមាត់លើលោកកិយ។

១៤- ផែនការចម្បងចងក្រងច្បាស់
អានទាំងក្មេងចាស់ដាស់ស្មារតី
អានគ្រប់បំណិនន័យចាស់ថ្មី
អានដោយឃ្មាតខ្មីខ្មែរគ្រប់ប្រាណ។

១៥- អំណានប្រៀបបានជាមាតា
បង្កើតរដ្ឋាត្រាថ្កើងថ្កាន
រុងរឿងខ្ពង់ខ្ពស់ព្រោះអំណាន
ជាតិសុខក្សេមក្សាន្តអានជាគុណ៕

អំណាន
READING